# វិធីទទួលបានការធ្វើតេស្តជំងឺ COVID-19

## មានវិធីជាច្រើនដើម្បីទទួលបានការធ្វើតេស្តជំងឺ COVID-19 នៅក្នុងខោនធី LA

### ការធ្វើតេស្តដោយមិនគិតថ្លៃ

**ប្រសិនបើអ្នកមានធានារ៉ាប់រងសុខភាព** ជម្រើសដែលល្អបំផុតនោះគឺត្រូវទាក់ទងទៅកាន់គ្រូពេទ្យ ឬផែនការថែទាំសុខភាពរបស់អ្នក ដើម្បីធ្វើតេស្ត។ គ្រូពេទ្យ និងផែនការថែទាំសុខភាពទាំងឡាយទទួលខុសត្រូវក្នុងការផ្តល់ការធ្វើតេស្តជំងឺ COVID-19 ដោយមិនគិតថ្លៃជូនដល់អ្នកជំងឺទាំងឡាយដែលបានប្រគល់ជូនឱ្យពួកគេជាអ្នកព្យាបាល។

**ប្រសិនបើម្ចាស់អាជីវកម្មឬកន្លែងការងារ ឬក៏សាលារៀនរបស់អ្នកតម្រូវចាំបាច់ឱ្យធ្វើតេស្តនោះ** សូមទាក់ទងទៅកាន់ម្ចាស់អាជីវកម្មឬកន្លែងការងារ ឬក៏សាលារៀនរបស់អ្នក ដើម្បីធ្វើតេស្ត។

**ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេនោះ សូមកុំព្រួយបារម្ភ។ មានវិធីជាច្រើនដើម្បីទទួលបានការធ្វើតេស្តដោយមិនគិតថ្លៃ នៅក្នុងខោនធី LA។**

## ទៅកាន់ទីតាំងធ្វើតេស្តមួយ

### ទីតាំងផ្សេងៗដែលដំណើរការដោយខោនធី

- ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេនោះ អ្នកអាចទទួលបានការធ្វើតេស្តជំងឺ COVID-19 ដោយមិនគិតថ្លៃ នៅតាមគ្លីនិកដែលមានតែគិលានុបដ្ឋាយិកាក្នុងមណ្ឌលសុខភាពសាធារណៈ (Public Health Center Nurse Only Clinic) ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។ ប្រសិនបើអ្នកមានធានារ៉ាប់រង អ្នកនឹងត្រូវការផ្តល់ព័ត៌មានផ្នែកធានារ៉ាប់រងនោះទៅពួកគេ។
- ការធ្វើតេស្តគឺមានផ្តល់ជូនសម្រាប់កុមារគ្រប់អាយុ។
- មានផ្តល់ជូនការធ្វើតេស្តរកទម្រង់មេរោគ (PCR) និងការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) ផងដែរ។
- ដើម្បីស្វែងយល់អំពីទីតាំងទាំងឡាយ និងម៉ោងដំណើរការ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/chs/NurseClinic.pdf (ឬជា ភាសាអេស្ប៉ាញ)។

### មណ្ឌលសុខភាព ឬឱសថស្ថាន (កន្លែងលក់ថ្នាំ)

សូមចូលទៅកាន់គេហទំព័រ ទីតាំងធ្វើតេស្តសម្រាប់ជំងឺ COVID-19 នៅតាមសហគមន៍ របស់ក្រសួងសេវាកម្មផ្នែកសុខភាព និងមនុស្សជាតិ (Department of Health and Human Services/HHS) ដើម្បីស្វែងរកការធ្វើតេស្តដែលគិតថ្លៃទាប ឬមិនគិតថ្លៃ។

- ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេនោះ មណ្ឌលសុខភាពអាចនឹងស្នើសុំឱ្យអ្នកចុះឈ្មោះទៅក្នុងកម្មវិធីរបស់រដ្ឋាភិបាលមួយ ដូចជាកម្មវិធីធានារ៉ាប់រង Medi-Cal ដើម្បីឱ្យពួកគេអាចទទួលបានការសងថ្លៃចំណាយសម្រាប់ការធ្វើតេស្តនោះវិញ។
- ប្រសិនបើអ្នកមានធានារ៉ាប់រង អ្នកអាចនឹងត្រូវការផ្តល់ព័ត៌មានផ្នែកធានារ៉ាប់រងនោះទៅពួកគេ។
- ប្រសិនបើអ្នកមិនអាច ឬមិនចង់ផ្តល់ព័ត៌មានផ្នែកធានារ៉ាប់រងទេនោះ ទីតាំងមួយចំនួនអាចនឹងគិតថ្លៃចំណាយពីអ្នកដោយផ្អែកទៅលើប្រាក់ចំណូល ឬស្ថានភាពប្រាក់កាសរបស់អ្នក។

ឱសថស្ថានជាច្រើនមានផ្តល់ជូនការធ្វើតេស្តជំងឺ COVID-19 ដោយមិនគិតថ្លៃ។ សូមចូលទៅកាន់គេហទំព័ររបស់ពួកគេ ឬក៏ទូរស័ព្ទទៅ ដើម្បីសាកសួរថាតើពួកគេតម្រូវចាំបាច់ឱ្យមានការណាត់ជួប ឬគិតថ្លៃចំណាយឬទេ។ សម្រាប់ព័ត៌មានអំពីឱសថស្ថានឯករាជ្យទាំងឡាយ សូមចូលទៅកាន់គេហទំព័រ doineedacovid19test.com។

## ទទួលបានឧបករណ៍ធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) ដោយមិនគិតថ្លៃ

អ្នកប្រមូលសំណាក និងធ្វើតេស្តដោយខ្លួនឯង។ ជាទូទៅ លទ្ធផលនៃ "ការធ្វើតេស្តដោយខ្លួនឯង (self-test)" ទាំងនេះអាចទទួលយកបានក្នុងរយៈពេលចាប់ពី 10 ទៅ 30 នាទី។ ប្រសិនបើឧបករណ៍ធ្វើតេស្តប្រភេទ antigen របស់អ្នកបានហួសកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) កំណត់ហើយ ក៏ឧបករណ៍ទាំងនេះអាចនឹងនៅតែប្រើប្រាស់បានផងដែរ។ សូមពិនិត្យមើលថាតើស្នាមខ្សែត្រួតពិនិត្យ (control line) នៅលើឧបករណ៍នោះគឺនៅអាចមើលឃើញ ហើយមានពណ៌ដូចគ្នាទៅនឹងរូបនៅក្នុងការណែនាំឬទេ។ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/covidselftest សម្រាប់ព័ត៌មានលម្អិត។

**តាមសំបុត្រពីរដ្ឋាភិបាលប្រទេស - សម្រាប់ក្រុមគ្រួសារទាំងអស់**
ក្រុមគ្រួសារនីមួយៗអាចស្នើសុំឱ្យមានការផ្ញើឧបករណ៍ធ្វើតេស្តដែលមិនគិតថ្លៃ ចំនួនបួនឧបករណ៍ ទៅឱ្យខ្លួន តាមសេវាកម្មប្រៃសណីយ៍នៃសហរដ្ឋអាមេរិក (US Postal Service) បាន។ សូមដាក់បញ្ជូនការស្នើសុំនៅលើគេហទំព័រ [covidtests.gov](covidtests.gov) ឬទូរស័ព្ទទៅកាន់លេខ 1-800-232-0233។

**តាមសំបុត្រពីនាយកដ្ឋានសុខភាពសាធារណៈ (Public Health) - សម្រាប់អ្នកដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ឬមិនអាចចាកចេញពីផ្ទះបាន**
អ្នកដែលរស់នៅក្នុងខោនធី LA ហើយដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ឬមិនអាចចាកចេញពីផ្ទះបានទេនោះ អាច ស្នើសុំ ឧបករណ៍ធ្វើតេស្តដែលមិនគិតថ្លៃ ចំនួនពីរឧបករណ៍។ ឧបករណ៍ធ្វើតេស្តនឹងផ្ញើទៅក្នុងអំឡុងពេល 5 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ)។

**នៅតាមទីតាំងចាក់ថ្នាំបង្ការដែលមានផ្តល់សេវាកម្មច្រើនប្រភេទរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Multi-Service Vaccination Site)**
ដើម្បីស្វែងយល់អំពីម៉ោងដំណើរការ និងទីតាំងទាំងឡាយ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/vaccinepods ឬទាញយក កាលវិភាគនៅទីនេះ។

**នៅក្នុងសហគមន៍របស់អ្នក**
បណ្ណាល័យ ទីកន្លែងទៅទទួលយកម្ហូបអាហារដោយមិនគិតថ្លៃ (food bank) មណ្ឌលសម្រាប់មនុស្សចាស់ និងអង្គការនៅក្នុងតំបន់ផ្សេងទៀតជាច្រើនមានផ្តល់ជូនឧបករណ៍ធ្វើតេស្តដែលមិនគិតថ្លៃសម្រាប់ទៅទទួលយក។ ស្វែងរកបណ្ណាល័យមួយ ដែលនៅជិតអ្នក។

**នៅតាមឱសថស្ថាន (កន្លែងលក់ថ្នាំ) ដោយប្រើប្រាស់កាតសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal ឬ Medicare របស់អ្នក**
សូមឱ្យមានកាតសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal ឬ Medicare សម្រាប់បុគ្គលម្នាក់ៗនៅក្នុងក្រុមគ្រួសាររបស់អ្នក។ សូមបង្ហាញកាតសមាជិកនោះទៅកាន់ឱសថការី (អ្នកលក់ថ្នាំ) នៅតុគិតលុយដែលទៅទទួលយកថ្នាំតាមវេជ្ជបញ្ជានោះ។ អ្នកអាចស្នើសុំឧបករណ៍ធ្វើតេស្តជំងឺ COVID-19 នៅតាមផ្ទះចំនួន 8 ឧបករណ៍សម្រាប់បុគ្គលម្នាក់ៗ ជារៀងរាល់ខែ។

**ការប្រើប្រាស់ធានារ៉ាប់រងសុខភាពផ្សេងៗទៀត**
មនុស្សភាគច្រើនដែលមានធានារ៉ាប់រងសុខភាព អាចទទួលឧបករណ៍ធ្វើតេស្តនៅផ្ទះបានរហូតដល់ចំនួន 8 ឧបករណ៍ជារៀងរាល់ខែ សម្រាប់បុគ្គលម្នាក់ៗនៅក្នុងផែនការថែទាំសុខភាពនោះ។ មានវិធីមួយចំនួនដើម្បីទទួលបានឧបករណ៍ធ្វើតេស្ត ដោយការប្រើប្រាស់ធានារ៉ាប់រងសុខភាព ដូចជា៖

- ឱ្យផ្ញើឧបករណ៍ធ្វើតេស្តទាំងនោះតាមសំបុត្រទៅអ្នក។
- ទៅទទួលយកឧបករណ៍ធ្វើតេស្តដែលមិនគិតថ្លៃនៅតាមឱសថស្ថាន (កន្លែងលក់ថ្នាំ) មួយ។
- ទិញឧបករណ៍ធ្វើតេស្តពីឱសថស្ថាន ឬហាងលក់ដូរមួយ ហើយរក្សាទុកវិក័យប័ត្ររបស់អ្នក។ អ្នកអាចដាក់បញ្ជូនវិក័យប័ត្ររបស់អ្នក ហើយអាចទទួលបានសំណងនៃការចំណាយខ្លះ ឬទាំងស្រុងមកវិញ។ ឧបករណ៍ធ្វើតេស្តនេះត្រូវតែ បានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA)។

ទូរស័ព្ទទៅកាន់ផែនការថែទាំសុខភាពរបស់អ្នក ឬចូលទៅកាន់គេហទំព័ររបស់ពួកគេ ដើម្បីទទួលបានការណែនាំ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ វិធីទទួលបានឧបករណ៍ធ្វើតេស្តជំងឺ COVID-19 នៅផ្ទះ ដែលអាចរកទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា ហើយដោយមិនគិតថ្លៃ របស់មជ្ឈមណ្ឌលសម្រាប់សេវាកម្ម Medicare និង Medicaid (CMS)។

## ទាក់ទងទៅកាន់គ្រូពេទ្យ ឬផែនការថែទាំសុខភាពរបស់អ្នក

ប្រសិនបើអ្នកមានធានារ៉ាប់រងនោះ មានការតម្រូវចាំបាច់ឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកចេញថ្លៃចំណាយនៃការធ្វើតេស្តទាំងស្រុង ប្រសិនបើគ្រូពេទ្យបញ្ជាឱ្យធ្វើតេស្ត។ អ្នកមិនចាំបាច់ត្រូវឱ្យមានរោគសញ្ញានានា ដើម្បីស្នើសុំធ្វើតេស្តនោះទេ។

ក្រុមហ៊ុនធានារ៉ាប់រងអាចនឹង**មិន**ចេញថ្លៃចំណាយលើការធ្វើតេស្តជំងឺ COVID-19 ទេ ប្រសិនបើការធ្វើតេស្តនេះត្រូវបានធ្វើឡើងជាផ្នែកមួយនៃកម្មវិធីវិលត្រឡប់ទៅធ្វើការវិញ (return-to-work program) របស់បុគ្គលិកម្នាក់។ ប្រសិនបើម្ចាស់អាជីវកម្មឬកន្លែងការងាររបស់អ្នកតម្រូវចាំបាច់ឱ្យធ្វើតេស្តនោះ សូមទាក់ទងទៅកាន់ម្ចាស់អាជីវកម្មឬកន្លែងការងាររបស់អ្នក។

## ការធ្វើតេស្តសម្រាប់កុមារ

- ប្រសិនបើកូនរបស់អ្នកមានរោគសញ្ញានានា ការទៅទទួលយកការធ្វើតេស្តពីគ្រូពេទ្យរបស់ពួកគេ ឬមណ្ឌលសុខភាពនៅក្នុងតំបន់ គឺជាជម្រើសដ៏ល្អបំផុត។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកគ្រូពេទ្យ សូមទូរស័ព្ទទៅកាន់លេខ 2-1-1 ឬចូលទៅកាន់គេហទំព័រ 211LA។ អ្នកក៏អាចស្វែងរកមណ្ឌលសុខភាពមួយដែលនៅជិតអ្នកបានផងដែរ នៅលើគេហទំព័រ HRSA.gov។
- ទីតាំងជាច្រើនដែលបានឧបត្ថម្ភដោយខោនធីធ្វើតេស្តសម្រាប់កុមារគ្រប់អាយុ។ ប៉ុន្តែសូមពិនិត្យមើលឡើងវិញ មុននឹងអ្នកធ្វើដំណើរទៅ។
- កម្រិតអាយុនៅតាមឱសថស្ថាន (កន្លែងលក់ថ្នាំ) ផ្សេងៗមានភាពខុសគ្នា - Walmart/Quest Diagnostics ធ្វើតេស្តចាប់ពីអាយុ 2 ឆ្នាំឡើងទៅ CVS Health និង Walgreens ធ្វើតេស្តចាប់ពីអាយុ 3 ឆ្នាំឡើងទៅ ហើយ Rite Aid ធ្វើតេស្តចាប់ពីអាយុ 4 ឆ្នាំឡើងទៅ។ សម្រាប់ឱសថស្ថានឯករាជ្យទាំងឡាយ សូមចូលទៅកាន់គេហទំព័រ doineedacovid19test.com។
- ប្រសិនបើអ្នកមានគម្រោងនឹងប្រើប្រាស់ឧបករណ៍ធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) សូមពិនិត្យប្រអប់ឧបករណ៍នោះឡើងវិញ ដើម្បីមើលកម្រិតអាយុ។